# របាយការណ៍វិភាគ
# មតិយោបល់សាធារណៈ

## ការបង្ហោះលើទំព័រហ្វេសប៊ុករបស់ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ករណីគ្រោះថ្នាក់ចរាចរណ៍ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៦ នៅគីឡូម៉ែត្រលេខ៦ | វិភាគលើមតិយោបល់សាធារណៈចំនួន ៣.៧៤៥

**វិសាលភាពនៃការវិភាគ**

ទំនុកចិត្តលើអាជ្ញាធរ | អំណាច និង ច្បាប់ | ការចង់ឃើញរបស់សាធារណជន

កាលបរិច្ឆេទ៖ ថ្ងៃទី ៣០ ខែមីនា ឆ្នាំ ២០២៦

អ្នកវិភាគ និងសរសេររបាយការណ៍៖ ង៉ែត ម៉ូសេ

# សេចក្តីសង្ខេបរបាយការណ៍

**នៅល្ងាចថ្ងៃទី ១៨ ខែមីនា ឆ្នាំ ២០២៦** អ្នកបើកបរក្នុងស្ថានភាពស្រវឹងម្នាក់បានបុកក្មេងប្រុសម្នាក់ បណ្តាលឱ្យរងរបួសធ្ងន់។ បុរសនៅក្នុងរថយន្ត ដែលសាធារណជនបានឃើញថាជាអ្នកបើកបរផ្ទាល់ និងត្រូវបានគេឮការប្រើប្រាស់ពាក្យសម្តីនិយាយថា៖ **«បុកស្លាប់ប៉ុណ្ណឹង បង់លុយឱ្យ ២ម៉ឺនដុល្លារបញ្ចប់រឿង»**។ សម្តីដ៏ក្រអឺតក្រទមនេះបានធ្វើឱ្យមហាជនផ្ទុះកំហឹងយ៉ាងខ្លាំង និងឈានដល់ការប្រើហិង្សាពីសំណាក់ហ្វូងមនុស្សទៅលើរូបគេ។ ក្នុងនោះដែរ ស្ត្រីម្នាក់បានយកទូរស័ព្ទ iPhone វាយក្បាលបុរសនោះ ដែលក្រោយមកបានក្លាយជា «មីម» (Meme) ដ៏ល្បីល្បាញពេញបណ្តាញសង្គម។ អាជ្ញាធរមូលដ្ឋានត្រូវបង្ខំចិត្តនាំខ្លួនរូបគេចេញពីហ្វូងមនុស្ស។

បុរសរូបនោះមានឈ្មោះថា **សាមីន វុត្ថារិទ្ធិ** អាយុ ២៨ ឆ្នាំ ជាកូនប្រុសរបស់អភិបាលស្រុកកងមាស ក្នុងខេត្តកំពង់ចាម និងក៏ជាមន្ត្រីបម្រើការនៅសាលាស្រុកកងមាសផងដែរ។ នៅថ្ងៃទី ២០ ខែមីនា អាជ្ញាធរបានអះអាងថា អ្នកបើកបរគឺជាស្ត្រីម្នាក់ ចំណែកបុរសរូបនោះគ្រាន់តែជាអ្នករួមដំណើរដែលស្រវឹងប៉ុណ្ណោះ។ ទោះជាយ៉ាងណាក៏ដោយ សាធារណជន នៅតែជឿជាក់ថា បុរសរូបនោះគឺជាអ្នកបើកបរពិតប្រាកដ។

**ការសិក្សានេះ ធ្វើការវិភាគលើមតិយោបល់សាធារណៈចំនួន ៣.៧៤៥ ដែលដកស្រង់ចេញពីការបង្ហោះលើទំព័រហ្វេសប៊ុកផ្លូវការរបស់ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ នាថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០២៦ តែប៉ុណ្ណោះ។**

| ៣,៧៤៥ | ៩៥.០% | ៧២៥ |
|---|---|---|
| ចំនួនមតិសរុបដែលបានធ្វើការវិភាគ | មិនទុកចិត្ត (នៃមតិចំនួនសរុប 2,086 ដែលបង្ហាញច្បាស់ពីគំនិតរបស់ពួកគេ) | ការបង្ហាញពីការ ចង់ឃើញ |

### ការឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវទាំង ៣

**សំណួរទី១៖ តើអ្នកបញ្ចេញមតិមានទំនុកចិត្តលើអាជ្ញាធរដែរឬទេ?**
**ចម្លើយ៖ អត់ទេ ។** ក្នុងចំណោមមតិសរុបចំនួន **៣.៧៤៥** មានមតិចំនួន **២.០៨៦** បានបង្ហាញពីគំនិតច្បាស់លាស់។ ក្នុងចំណោមមតិទាំង **២.០៨៦** នោះ មានរហូតដល់ **៩៥,០%** (**១.៩៨១** មតិ) បង្ហាញពីការមិនទុកចិត្ត ឬមានមន្ទិលសង្ស័យ។ មានត្រឹមតែ **៥,០%** ប៉ុណ្ណោះ (**១០៥** មតិ) ដែលបង្ហាញពីក្តីសង្ឃឹម ឬទំនុកចិត្ត។ ចំណែកមតិយោបល់ចំនួន **១.៦៥៩** ផ្សេងទៀត គឺ មតិខ្លីៗពេក ឬជាមតិមិនអាចធ្វើការបែងចែកប្រភេទបាន។

**សំណួរទី២៖ តើអ្នកបញ្ចេញមតិយល់ឃើញយ៉ាងណា ចំពោះ "អំណាចនៅពីលើច្បាប់"?**
**ចម្លើយ៖** ប្រជាពលរដ្ឋជឿជាក់ថា **ទឹកប្រាក់ និងអំណាចនយោបាយ គឺស្ថិតនៅពីលើច្បាប់**។ ពួកគេលើកឡើងថា អ្នកមានទ្រព្យសម្បត្តិ និងបុណ្យស័ក្តិអាច "ទិញយុត្តិធម៌" បាន ហើយកងកម្លាំងនគរបាលបម្រើតែអ្នកមានអំណាច ប៉ុន្តែមិនបម្រើប្រជាពលរដ្ឋម្ចាស់ឆ្នោតនោះទេ។ អ្នកបញ្ចេញមតិជាច្រើនបានចាត់ទុកថា ករណីបែបនេះគឺជា "រូបភាពដដែលៗ" (ឬជាទម្លាប់អាក្រក់ដដែលៗ) ដែលតែងតែកើតមាននៅក្នុងសង្គមកម្ពុជា។

**សំណួរទី៣៖ តើអ្នកបញ្ចេញមតិចង់ឃើញអ្វីខ្លះ?**
**ចម្លើយ៖** ការចង់ឃើញចម្បងបំផុតរបស់អ្នកបញ្ចេញមតិ គឺការ **ពិនិត្យមើលរូបភាពកាមេរ៉ាសុវត្ថិភាព (CCTV)** (មានចំនួន ១៩៥ មតិ)។ ក្រៅពីនេះ ប្រជាពលរដ្ឋក៏បានទាមទារនូវចំណុចសំខាន់ៗដូចជា៖

- យុត្តិធម៌សម្រាប់ជនរងគ្រោះ (១៩៩ មតិ)
- ការដាក់ពន្ធនាគារអ្នកបើកបរពិតប្រាកដ (៨៦ មតិ)
- ការស៊ើបអង្កេតឱ្យបានត្រឹមត្រូវ និងហ្មត់ចត់ (៥១ មតិ)
- និងការដាក់ទណ្ឌកម្មទៅតាមច្បាប់ជាធរមាន (៤៩ មតិ)។

# ១. សារតានៃអង្គហេតុ

## ១.១ ដំណើររឿងនៃព្រឹត្តិការណ៍

នៅល្ងាចថ្ងៃទី ១៨ ខែមីនា ឆ្នាំ ២០២៦ ឈ្មោះ **សាមីន វុត្ថារិទ្ធិ** ភេទប្រុស អាយុ ២៨ ឆ្នាំ ដែលអ្នកបញ្ចេញមតិយល់ថាបានបើកបររថយន្តក្នុងស្ថានភាពស្រវឹង ហើយបានបុកក្មេងប្រុសម្នាក់ បណ្ដាលឱ្យរងរបួសធ្ងន់ធ្ងរ[1]។ បន្ទាប់ពីកើតមានគ្រោះថ្នាក់ភ្លាមៗ បុរសរូបនោះត្រូវបានគេឮសម្ដីពោលថា៖ **«បុកស្លាប់ប៉ុណ្ណឹង បង់លុយឱ្យ ២ម៉ឺនដុល្លារបញ្ចប់រឿង»**។ សម្ដីដ៏ក្រអឺតក្រទមដែលបង្ហាញពីការមើលងាយអាយុជីវិតមនុស្សនេះ បានធ្វើឱ្យមហាជនដែលនៅកន្លែងកើតហេតុផ្ទុះកំហឹងយ៉ាងខ្លាំង។ ក្នុងនោះដែរ មានស្ត្រីម្នាក់បានយកទូរស័ព្ទ iPhone វាយក្បាលបុរសនោះ ហើយហ្វូងមនុស្សបាននាំគ្នាប្រើហិង្សាទៅលើរូបគេ រហូតដល់អាជ្ញាធរមូលដ្ឋានត្រូវបង្ខំចិត្តអន្តរាគមន៍ ដើម្បីនាំខ្លួនគេចេញពីកន្លែងកើតហេតុ។ រូបភាពនៃការយក iPhone វាយក្បាលនោះ បានក្លាយជា «មីម» (Meme) ល្បីល្បាញនៅលើបណ្ដាញសង្គម។

បុរសរូបនេះ គឺជាកូនប្រុសរបស់អភិបាលស្រុកកងមាស[2] ខេត្តកំពង់ចាម ហើយរូបគេក៏ជាមន្ត្រីបម្រើការងារនៅសាលាស្រុកកងមាសផងដែរ[3]។

## ១.២ កាលប្បវត្តិនៃអង្គហេតុ

| កាលបរិច្ឆេទ | ព្រឹត្តិការណ៍ |
|---|---|
| **១៨ មីនា** | អ្នកបើកបរក្នុងស្ថានភាពស្រវឹងម្នាក់បានបុកក្មេងប្រុសម្នាក់ បណ្ដាលឱ្យរងរបួសធ្ងន់ធ្ងរ។ បុរសម្នាក់ដែលប្រជាជនអះអាងថាជាអ្នកបើកបររថយន្តបង្កគ្រោះថ្នាក់ បាននិយាយ បុកស្លាប់ប៉ុណ្ណឹង បង់លុយឱ្យ ២ម៉ឺនដុល្លារបញ្ចប់រឿង។ មានមហាជនជាច្រើនបានខឹងសម្បានឹងប្រើពាក្យសម្ដីមើលងាយជីវិតមនុស្ស ហើយមានស្ត្រីម្នាក់បានយកទូរស័ព្ទ iPhone វាយក្បាលបុរសម្នាក់នោះចេញឈាម មុនពេលអាជ្ញាធរមូលដ្ឋានអន្តរាគមន៍នាំខ្លួនបុរសនោះចេញ។ |
| **២០ មីនា** | ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានប្រកាសថា[4] ពួកគេកំពុងស៊ើបអង្កេតករណីគ្រោះថ្នាក់ចរាចរណ៍នេះ។ សេចក្ដីប្រកាសបានអះអាង ដោយយោងតាមការបំភ្លឺរបស់ភាគីរថយន្តបង្កបានឆ្លើយចំពោះមុខសមត្ថកិច្ចឲ្យដឹងថាអ្នកបើកបររថយន្តបង្កជាស្ត្រី។ ការ |

[1] RFI Khmer (2026, March 24). *តុលាការក្រុងភ្នំពេញបានសម្រេចដោះលែងកូនប្រុសអភិបាលស្រុកកងមាសឱ្យមានសេរីភាព.* www.facebook.com. https://www.facebook.com/reel/2432033050646447

[2] Ministry of Interior (2020, February 6). *អភិបាលខេត្តកំពង់ចាម ជំរុញដល់អភិបាលស្រុកកងមាស ទេីប ចូលកាន់មុខតំណែង ត្រូវខិតខំអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាល សាធារណៈ.* www.Interior.gov.kh. https://www.interior.gov.kh/report/detail/4246

[3] លី ចន្ទូ (2026, March 19). *ព្រោះតែបោះសម្ដីថា «ងាប់សង២ម៉ឺនដុល្លារ» មន្ត្រីរដ្ឋបាលសាលាស្រុកកងមាសម្នាក់ ត្រូវពលរដ្ឋព្ទួតវាយបែកក្បាល.* https://Troryorng.com. https://troryorng.com/article/325223.html

[4] ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ (2026, March 20). *ករណីបញ្ហាគ្រោះថ្នាក់ចរាចរណ៍នៅសង្កាត់គីឡូម៉ែត្រលេខ៦.* www.Facebook.com. https://www.facebook.com/commissariatofphnompenhmuniciplepolice/posts/pfbid02J9SbGY8xzWf5U7mkKtbpcWoyqh8nLwm1FNQNP13by69fwhqsSehddKUP5bFs85Nhl

| | |
|---|---|
| | បង្ហោះព័ត៌មានអំពីករណីនេះលើទំព័រហ្វេសប៊ុករបស់ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ គឺជាកម្មវត្ថុនៃការវិភាគមតិយោបល់នៅក្នុងការសិក្សានេះ។ |
| **២១ មីនា** | ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានបង្ហាញវីដេអូពីកាមេរ៉ាសុវត្ថិភាព[5] (មិនមែនជាវីដេអូនៅកន្លែងកើតហេតុផ្ទាល់នោះទេ) ដោយបង្ហាញឃ្លីបខ្លីមួយនៃស្ត្រីម្នាក់ដែលបានអះអាងថាខ្លួនគឺជាអ្នកបើកបរ។ |
| **២៣ មីនា** | មានការបង្ហោះវីដេអូបុរសនិងស្ត្រីទាំងពីរនាក់ធ្វើការសុំទោសជាសាធារណៈលើទំព័រហ្វេសប៊ុក ដែលមានឡូហ្គោរបស់ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។ វីដេអូនេះ មិនឃើញមានក្នុងទំព័រហ្វេសប៊ុករបស់ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញនោះទេ ប៉ុន្តែត្រូវបានអ្នកប្រើប្រាស់បណ្តាញសង្គម និងសារព័ត៌មានធ្វើផ្សេងទៀតយកទៅបង្ហោះបន្ត[6]។ នៅថ្ងៃដដែលនោះ អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ចេញសេក្តីប្រកាសបើកការស៊ើបអង្កេតលើករណីនេះ[7]។ |
| **២៤ មីនា** | ចៅក្រមស៊ើបសួរ លោក តុប ឈុនសុង បានចេញដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្នលើស្ត្រីអ្នកបើកបរ ដើម្បីបន្តការស៊ើបអង្កេត។ អ្នកនាំពាក្យនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានប្រកាសថា ផ្អែកតាមការស៊ើបអង្កេតរបស់នគរបាលចរាចរណ៍ ជនសង្ស័យជាស្ត្រី (ឈ្មោះ សុខ ច័ន្ទបូណ៌មី ហៅ យាន) គឺជាអ្នកបើកបរ។ តំណាងអយ្យការបានចោទប្រកាន់ស្ត្រីរូបនោះពីបទ «បើកបរបង្កគ្រោះថ្នាក់ចរាចរណ៍បណ្តាលឱ្យរបួសអ្នកដទៃ» (ក្នុងស្ថានភាពស្រវឹងមានជាតិអាល់កុល ០.៥២mg/L និងបើកគេចខ្លួនពីកន្លែងកើតហេតុ) តាមបញ្ញត្តិមាត្រា ៨៣ កថាខណ្ឌទី២ ចំណុច ខ និងចំណុច ឃ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងបានបញ្ជូនសំណុំរឿងនេះ ទៅចៅក្រមស៊ើបសួរសាលា ដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការបន្តតាមនីតិវិធី[8]។ |

[5] Fresh News (2026, March 21). *ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បង្ហាញកាមេរ៉ាសុវត្ថិភាពបង្ហាញថា កូនអភិបាលស្រុកកងមាស មិនមែនជាអ្នកបើករថយន្តបង្កគ្រោះថ្នាក់ចរាចរណ៍ទេ, អ្នកបើកគឺជាស្ត្រី*. www.Freshnews.com.kh. https://freshnews.com.kh/localnews/421634-2026-03-21-12-38-09

[6] VAYO FM Radio (2026, March 23). *ជនបង្កគ្រោះថ្នាក់ចរាចរណ៍ បើកបុកកុមារាម្នាក់ឱ្យរងរបួសធ្ងន់ នៅសង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ លើកដៃសំពះ និងលុតជង្គង់សុំទោស*. www.Facebook.com. https://www.facebook.com/watch/?v=1462829695247832

[7] The Ministry of Information (2026, March 24). *អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ចេញសេចក្តីប្រកាសអំពីចំណាត់ការលើករណីគ្រោះថ្នាក់ចរាចរណ៍នៅខណ្ឌឫស្សីកែវ កាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៦*. www.facebook.com. https://www.facebook.com/TheMinistryOfInformation/posts/pfbid0gQxmDkAyALzJ5cc3zFURqE2vD6KUfTwXqqoVYTWAerCs6xpHYNiFGDRL8sYf3Gjsl

[8] Fresh News (2026, March 24). *អ្នកនាំពាក្យនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ចេញសេចក្តីប្រកាសអំពីចំណាត់ការលើករណីគ្រោះថ្នាក់ចរាចរណ៍នៅខណ្ឌឫស្សីកែវ ដែលពាក់ព័ន្ធនឹងកូនប្រុសអភិបាលស្រុកកងមាស*. www.Freshnews.com.kh. https://freshnews.com.kh/localnews/421922-2026-03-24-12-44-39

## វិសាលភាពនៃការវិភាគ

ការសិក្សានេះ ធ្វើការវិភាគតែទៅលើមតិយោបល់របស់សាធារណជន ដែលបានដកស្រង់ចេញពីការបង្ហោះលើទំព័រហ្វេសប៊ុកផ្លូវការរបស់ **ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ** កាលពីថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០២៦ តែប៉ុណ្ណោះ។ មតិយោបល់ទាំងនេះ ត្រូវបានប្រមូលយកមកវិភាគ ចន្លោះថ្ងៃទី២០-២១ ខែមីនា ឆ្នាំ២០២៦ មុនពេលដែលមានការវិវត្តថ្មីៗនៃករណីនេះ (ដូចជា ការបង្ហាញភស្តុតាងវីដេអូបន្ថែម, ចំណាត់ការរបស់តុលាការ និងការចោទប្រកាន់ជាផ្លូវការ)។ មតិយោបល់របស់សាធារណជនទាំងនេះ ឆ្លុះបញ្ចាំងពីប្រតិកម្មចំពោះសេចក្តីថ្លែងការណ៍ដំបូងរបស់សមត្ថកិច្ច ដែលបានអះអាងថា អ្នកបើកបរគឺជាស្ត្រី។ ខ្ញុំស្វែងរកវិដេអូសុំទោសរបស់ឈ្មោះ សាមីន វុត្ថារិទ្ធិ និង ឈ្មោះ សុខ ច័ន្ទបូណ៌មី ហៅ យាន ដែលមានស្លាកឡូហ្គូសំគាល់របស់ស្នងការលើវិដេអូ ពីទំព័រហ្វេសប៊ុកផ្លូវការរបស់ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ក្នុងអំឡុងពេលធ្វើការវិភាគនេះ ដើម្បីប្រៀបធៀបនៃការវិត្តរបស់អ្នកបញ្ចេញមតិ ប៉ុន្តែរកផូសវិដេអូនោះមិនឃើញមិនឃើញនោះទេ។

**ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ**
March 20 at 5:53 PM ·

ចំពោះករណីបញ្ហាគ្រោះថ្នាក់ចរាចរណ៍នៅសង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ កាលពីយប់ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៦ បណ្តាលឲ្យក្មេងប្រុស០១នាក់រងរបួសធ្ងន់ អ្នកបើកបររថយន្តនិងអ្នករួមដំណើរប្រុសស្រីទាំង០២នាក់ កំពុងត្រូវបានសមត្ថកិច្ចជំនាញការិយាល័យនគរបាលចរាចរណ៍ផ្លូវគោកនាំខ្លួនយកមកសាកសួរតាមច្បាប់។

ជាមួយគ្នានេះបើយោងតាមការបំភ្លឺរបស់ភាគីរថយន្តបង្កបានឆ្លើយចំពោះមុខសមត្ថកិច្ចឲ្យដឹងថាអ្នកបើកបររថយន្តបង្កជាស្ត្រី ដោយមុនពេលកើតហេតុស្ត្រីនោះបានបើករថយន្តចេញពីកន្លែងផឹកស៊ីជាមួយបុរសដែលរួមដំណើរពីហាងមួយកន្លែងក្នុងខណ្ឌសែនសុខ។

ទោះបីយ៉ាងណាករណីនេះ សមត្ថកិច្ចកំពុងបន្តអង្កេតស្រាវជ្រាវតាមជំនាញ បច្ចេកទេស ក្នុងគោលដៅសុក្រឹតភាពនៃការទទួលខុសត្រូវក្នុងនាមជាអ្នកបើកបរបង្កហេតុ ដោយអនុលោមតាមនីតិវិធីកំណត់ក្នុងច្បាប់ មុននឹងបញ្ជូនសំណុំរឿងទៅតុលាការឆាប់ៗនេះ ដើម្បីពិនិត្យសម្រេចជាសមត្ថកិច្ច៕




*រូបភាព: រូបភាពថតអេក្រង់ពីទំព័រហ្វេសប៊ុករបស់ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ដែលបានផុសពីករណីគ្រោះថ្នាក់ចរាចរណ៍កាលពីថ្ងៃទី១៨ ខែមីនា នៅគីឡូម៉ែត្រលេខ៦។ ជាផូសដែលត្រូវបានដកស្រង់នូវមតិមកពីការវិភាគ។*

# ២.ទិន្នន័យ និង វិធីសាស្ត្រ

| ប្រភេទទិន្នន័យ | ព័ត៌មាននៃប្រភេទទិន្នន័យ |
|---|---|
| **ប្រភពទិន្នន័យ (មតិយោបល់)** | ហ្វេសប៊ុកផូស របស់ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ (Post ID: 1487473616072746) |
| **សរុបមតិយោបល់** | ៣,៧៤៥ មតិសាធារណៈ |
| **ការចាត់ថ្នាក់ មតិ** | ចែកជា ៦ផ្នែក: កម្រិតនៃទំនុកចិត្ត, ហេតុផលនៃទំនុកចិត្ត, អំណាច និង ច្បាប់, ការចង់ឃើញរបស់សាធារណៈ, ក្រុមនៃប្រភេទមតិ, ទំនោរអារម្មណ៍ |

## ២.១ វិធីសាស្ត្រនៃការសិក្សា

មតិយោបល់សរុបចំនួន **៣.៧៤៥** ត្រូវបានប្រមូលដកស្រង់ចេញពីការបង្ហោះលើទំព័រហ្វេសប៊ុករបស់ **ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ** នាថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០២៦។ មតិយោបល់ដើមដែលសរសេរជាភាសាខ្មែរ ត្រូវបានបកប្រែទៅជាភាសាអង់គ្លេសសម្រាប់ការវិភាគ។ មតិយោបល់នីមួយៗត្រូវបានបែងចែកប្រភេទ ដោយប្រើប្រាស់វិធីសាស្ត្រផ្ទៀងផ្ទាត់ពាក្យគន្លឹះ (Keyword-based pattern matching) ជាមួយនឹងក្បួនដោះស្រាយ (Regex patterns) ជាភាសាអង់គ្លេសជាង ៨០ ពាក្យគន្លឹះ គ្របដណ្តប់លើ ៦ ប្រភេទខុសៗគ្នា។

ការវិភាគត្រូវបានធ្វើឡើងចំនួន ៤ ជំនាន់ ដើម្បីបង្កើនភាពត្រឹមត្រូវនៃលទ្ធផល៖

- **ដំណាក់កាលទី ១៖** ប្រើប្រាស់ពាក្យគន្លឹះជាភាសាខ្មែរចំនួន ៣០ លំនាំពាក្យគន្លឹះ។
- **ដំណាក់កាលទី ២៖** ប្រើប្រាស់ពាក្យគន្លឹះជាភាសាខ្មែរចំនួន ៥៥ លំនាំពាក្យគន្លឹះ។
- **ដំណាក់កាលទី ៣៖** ប្រើប្រាស់ក្បួនដោះស្រាយជាភាសាអង់គ្លេសជាង ៥០ លំនាំពាក្យគន្លឹះ។
- **ដំណាក់កាលទី ៤ (របាយការណ៍នេះ)៖** ប្រើប្រាស់ក្បួនដោះស្រាយជាភាសាអង់គ្លេសសម្រាប់លំនាំពាក្យគន្លឹះជាង ៨០ ដោយបន្ថែមការវិភាគលើ **«ការនិយាយបញ្ចិតបញ្ចៀង (Sarcasm)»**, **«ការប្រើប្រាស់រូបសញ្ញាអារម្មណ៍ (Emoji)»**, **«សំណួរបញ្ឆោស (Rhetorical questions)»** និង **«ភាសានិយាយក្រៅផ្លូវការ (Colloquial expressions)»**។

ដំណាក់កាលទី ៤ នេះ ផ្តល់នូវលទ្ធផលដែលមានភាពសុក្រឹតច្រើនបំផុត ដោយសារការប្រើប្រាស់ក្បួនដោះស្រាយជាភាសាអង់គ្លេស អាចយល់ពីអត្ថន័យ និងបរិបទបានស៊ីជម្រៅជាងការប្រើប្រាស់ពាក្យគន្លឹះទោលជាភាសាខ្មែរ។

## ២.២ កម្រិតកំណត់នៃការសិក្សា

មតិយោបល់ចំនួន **៤៤,៣%** (ស្មើនឹង **១.៦៥៩** ក្នុងចំណោម **៣.៧៤៥** មតិ) ត្រូវបានចាត់ថ្នាក់ជាប្រភេទ **«មតិកណ្តាល ឬមិនច្បាស់លាស់»**។ មតិយោបល់ទាំងនេះ ភាគច្រើនគឺជាមតិប្រតិកម្មខ្លីៗបំផុត ដូចជាការប្រើប្រាស់តែរូបសញ្ញាអារម្មណ៍ (Emoji), ការឆ្លើយតបត្រឹមមួយពាក្យ ឬមតិយោបល់ដែលមិនពាក់ព័ន្ធនឹងប្រធានបទ ដែលមិនមានព័ត៌មានគ្រប់គ្រាន់សម្រាប់ធ្វើការបែងចែកប្រភេទ។ ហេតុដូច្នេះ លទ្ធផលនៃការវិភាគនេះ គឺផ្អែកទៅលើមតិ

យោបល់ចំនួន **២.០៨៦** ដែលបានបង្ហាញពីទស្សនៈច្បាស់លាស់តែប៉ុណ្ណោះ។ លើសពីនេះទៅទៀត ការបកប្រែពីភាសាខ្មែរទៅជាភាសាអង់គ្លេស អាចធ្វើឱ្យបាត់បង់អត្ថន័យដើមខ្លះៗ ជាពិសេសចំពោះការនិយាយបញ្ឆិតបញ្ឆៀង (Sarcasm), ភាសាសាមញ្ញ (Slang) និងការប្រើប្រាស់ពាក្យជាគ្រាមភាសា។

# ៣. សំណួរទី១៖ តើសាធារណជនមានទំនុកចិត្តលើអាជ្ញាធរដែរឬទេ?

95.0%

នៃមតិយោបល់ដែលបង្ហាញពីការមិនទុកចិត្ត ឬមន្ទិលសង្ស័យ

1,981 ក្នុងចំណោម 2,086 មតិដែលមានជំហរច្បាស់លាស់

ក្នុងចំណោមមតិយោបល់ចំនួន **២.០៨៦** ដែលបានបង្ហាញពីទស្សនៈច្បាស់លាស់ មានមតិចំនួន **១.៩៨១ (៩៥,០%)** បានបង្ហាញពី **ការមិនទុកចិត្ត ឬមន្ទិលសង្ស័យ**។ មានត្រឹមតែ **១០៥** មតិប៉ុណ្ណោះ **(៥,០%)** ដែលបង្ហាញពី **ក្តីសង្ឃឹម ឬទំនុកចិត្ត**។ ចំណែកឯមតិយោបល់ចំនួន **១.៦៥៩** ផ្សេងទៀត ត្រូវបានចាត់ថ្នាក់ជាមតិកណ្តាល ឬមិនច្បាស់លាស់។

## ការបែកចែកប្រភេទនៃកម្រិតទំនុកចិត្ត



## ប្រភេទនៃទំនុកចិត្ត (មិនរាប់បញ្ចូលមតិកណ្ដាល ឬមិនច្បាស់លាស់)




ក្រោយសសរផ្ដេកនេះ បានដកចេញនូវមតិយោបល់កណ្ដាល ឬមិនច្បាស់លាស់ ចំនួន **១.៦៥៩** និងបង្ហាញតែមតិយោបល់ចំនួន **២.០៨៦** ដែលមានទស្សនៈច្បាស់លាស់តែប៉ុណ្ណោះ។ មតិយោបល់កណ្ដាលភាគច្រើនគឺពាក្យខ្លីៗ (ដូចជាការប្រើពាក្យមួយម៉ាត់, រូបសញ្ញាអារម្មណ៍ ឬមតិមិនពាក់ព័ន្ធ) ដែលមិនមានគោលជំហរច្បាស់លាស់លើបញ្ហាទំនុកចិត្ត។ បន្ទាប់ពីដកមតិទាំងនោះចេញ យើងឃើញថា **«ការមិនទុកចិត្ត» (១.៣៦៣ មតិ)** គឺជាក្រុមដែលធំជាងគេបំផុត បន្ទាប់មកគឺ **«មតិមានលក្ខខណ្ឌ ឬមន្ទិលសង្ស័យ» (៥១៣ មតិ)**។ មានមនុស្សត្រឹមតែ **១០៥ នាក់** ប៉ុណ្ណោះ ដែលបានបង្ហាញពីក្ដីសង្ឃឹម ឬទំនុកចិត្ត។

### មតិអវិជ្ជមាន និងវិជ្ជមាន




រង្វង់ខាងឆ្វេងបង្ហាញពីមតិអវិជ្ជមានសរុប៖ **ការមិនទុកចិត្ត (១.៣៦៣)** + **មតិមានលក្ខខណ្ឌ/មន្ទិលសង្ស័យ (៥១៣)** + **ការមិនទុកចិត្តខ្លាំង (១០៥)** = សរុបចំនួន **១.៩៨១** មតិ។ ចំណែកឯរង្វង់ខាងស្ដាំបង្ហាញពីមតិវិជ្ជមានសរុប៖ **មានសង្ឃឹមដោយប្រុងប្រយ័ត្ន (នៅមានមន្ទិលសង្ស័យ) (១០៤)** + **ការទុកចិត្ត/មានសង្ឃឹម (១)** = សរុបចំនួន **១០៥** មតិ។ គម្លាតនេះគឺមានទំហំធំធេងណាស់។ ក្នុងចំណោមមនុស្ស ២០ នាក់ដែលមានទស្សនៈ

ច្បាស់លាស់ មានត្រឹមតែ ១ នាក់ប៉ុណ្ណោះដែលមានក្ដីសង្ឃឹម ចំណែកឯ ១៩ នាក់ផ្សេងទៀត គឺមិនមានទំនុកចិត្តលើអាជ្ញាធរនោះទេ។

### តារាងទិន្នន័យនៃកម្រិតទំនុកចិត្ត

តារាងខាងក្រោមនេះបង្ហាញពីកម្រិតនៃទំនុកចិត្តទាំង ៦ ប្រភេទ។ **«ការមិនទុកចិត្ត» (Distrust):** មានន័យថាមតិយោបល់នោះបង្ហាញយ៉ាងច្បាស់ថា បុគ្គលនោះមិនមានទំនុកចិត្តលើអាជ្ញាធរឡើយ។ **«មតិមានលក្ខខណ្ឌ ឬមន្ទិលសង្ស័យ» (Conditional/Skeptical):** មានន័យថាបុគ្គលនោះចង់ឃើញភស្តុតាងជាមុនសិន (ទើបសម្រេចចិត្តជឿ)។ **«មតិកណ្ដាល ឬមិនច្បាស់លាស់» (Neutral/Unclear):** មានន័យថាមតិយោបល់នោះខ្លីពេក ឬមិនពាក់ព័ន្ធនឹងប្រធានបទ ដែលមិនអាចធ្វើការបែងចែកប្រភេទបាន។

| ប្រភេទកម្រិតទំនុកចិត្ត | ចំនួនមតិ | ភាគរយ | ទិសដៅ |
|---|---|---|---|
| មិនទុកចិត្ត | ១,៣៦៣ | 36.4% | **អវិជ្ជមាន** |
| មានលក្ខខណ្ឌ / មន្ទិលសង្ស័យ | ៥១៣ | 13.7% | **អវិជ្ជមាន** |
| មានសង្ឃឹមតែនៅមានមន្ទិលសង្ស័យ | ១០៤ | 2.8% | **វិជ្ជមាន** |
| គ្មានទំនុកចិត្តទាល់តែសោះ | ១០៥ | 2.8% | **អវិជ្ជមាន** |
| ទុកចិត្ត / មានសង្ឃឹម | ១ | 0.0% | **វិជ្ជមាន** |
| **កណ្ដាល / មិនច្បាស់លាស់** | **១,៦៥៩** | **៤៤.៣%** | — |

#### មូលហេតុដែលសាធារណជនមិនទុកចិត្តលើអាជ្ញាធរ

១. ប៉ូលីសបានអះអាងថា ស្ត្រីម្នាក់ជាអ្នកបើកបរ ប៉ុន្តែប្រជាពលរដ្ឋអះអាងថា បុរសគឺជាអ្នកបើកបរ។

២. បុរសនោះគឺជាកូនប្រុសរបស់អភិបាលស្រុកកងមាស ខេត្តកំពង់ចាម។ មហាជនមើលឃើញថា នេះគឺជាការប្រើប្រាស់អំណាចនយោបាយដើម្បីការពារបក្ខពួក។

៣. បុរសរូបនោះបានអះអាងទាំងក្រអឺតក្រទមថា **«បុកស្លាប់ប៉ុណ្ណឹង បង់លុយឱ្យ ២ម៉ឺនដុល្លារបញ្ចប់រឿង»**។ មហាជនមើលឃើញថានេះគឺជាឥរិយាបថដែលបង្ហាញពីការមើលងាយជីវិតមនុស្សយ៉ាងធ្ងន់ធ្ងរ។

៤. រូបភាពដដែលៗនៃអយុត្តិធម៌៖ អ្នកបញ្ចេញមតិជាច្រើនលើកឡើងថា នេះមិនមែនជាលើកទីមួយនោះទេ។ ពួកគេមើលឃើញនូវ «រូបភាពដដែលៗ» ដែលអ្នកមានអំណាចតែងតែអាចគេចផុតពីសំណាញ់ច្បាប់។

៥. មហាជនរិះគន់ថា ប៉ូលីសបម្រើតែអ្នកមានទ្រព្យសម្បត្តិ ប៉ុន្តែមិនបម្រើប្រជាពលរដ្ឋនោះទេ។ មតិខ្លះបានលើកឡើងថា ប៉ូលីស **«ស៊ីប្រាក់ខែរាស្ត្រ»** តែមិនបានជួយរកយុត្តិធម៌ឱ្យរាស្ត្រឡើយ។

៦. មហាជនយល់ឃើញថា ស្ត្រីជាដៃគូគ្រាន់តែជា **«អ្នករងគ្រោះជំនួស» (Scapegoat)** ប៉ុណ្ណោះ។ ពួកគេជឿថា អ្នកមានអំណាចតែងតែរកមនុស្សមកទទួលទោសជំនួសខ្លួនជានិច្ច។

*សូមមើល **ឧបសម្ព័ន្ធ ក** សម្រាប់មតិដើម ដែលគាំទ្រហេតុផលនីមួយៗ។*

### មូលហេតុដែលបុគ្គលមួយចំនួននៅតែមានក្ដីសង្ឃឹម

១. អ្នកបញ្ចេញមតិមួយចំនួនជឿជាក់ថា ប្រសិនបើមានការត្រួតពិនិត្យឱ្យបានត្រឹមត្រូវលើកាមេរ៉ាសុវត្ថិភាព ស្នាមមេដៃ និងសក្ខីកម្មពីសាក្សីនោះ ការពិតនឹងត្រូវលាតត្រដាងជាមិនខាន។

២. អ្នកបញ្ចេញមតិមួយចំនួនតូចបានលើកឡើងពីប្រសាសន៍ជាសាធារណៈរបស់ **លោកនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត** ដែលបានប្រកាសប្រឆាំងដាច់ខាតចំពោះករណីគ្រោះថ្នាក់ចរាចរណ៍បុកហើយរត់ ជាមូលហេតុដែលធ្វើឱ្យពួកគេនៅមានសង្ឃឹមលើការដោះស្រាយ។

៣. មតិយោបល់ខ្លះបានបង្ហាញពី «ទំនុកចិត្តដែលមានលក្ខខណ្ឌ» ពោលគឺពួកគេនឹងផ្ដល់ទំនុកចិត្តលើអាជ្ញាធរ **លុះត្រាតែ** មានការប្រើប្រាស់ភស្តុតាងត្រឹមត្រូវ និងច្បាស់លាស់ក្នុងការដោះស្រាយរឿងក្ដីនេះ។

*សូមមើល **ឧបសម្ព័ន្ធ ខ** សម្រាប់មតិដើម ពីអ្នកបញ្ចេញមតិដែលមានក្ដីសង្ឃឹម។*

# ៤. សំណួរទី២៖ តើមហាជនយល់ឃើញយ៉ាងណា ចំពោះ «អំណាចធំជាងច្បាប់»?

សំណួរនេះ ពិនិត្យទៅលើរបៀបដែលសាធារណជនមើលឃើញពីទំនាក់ទំនងរវាង **អំណាច ទឹកប្រាក់ និងច្បាប់**។ មតិយោបល់ជាច្រើននៅក្នុងទិន្នន័យ បានលើកឡើង និងជជែកដេញដោលគ្នាអំពីប្រធានបទនេះ។ អ្នកបញ្ចេញមតិជឿជាក់ថា ករណីនេះមិនមែនជារឿងគ្រោះថ្នាក់ចរាចរណ៍ធម្មតាមួយនោះទេ ប៉ុន្តែវាគឺជាឧទាហរណ៍ច្បាស់លាស់មួយ ដែលបង្ហាញថាអ្នកមានអំណាចអាចគេចផុតពីសំណាញ់ច្បាប់ ខណៈដែលប្រជាពលរដ្ឋសាមញ្ញមិនអាចធ្វើបាន។

បន្ទាប់ពីបានអាន និងវិភាគលើមតិយោបល់ទាំងអស់ យើងបានរកឃើញនូវលំនាំ (Patterns) ចំនួន ៦។ តារាងខាងក្រោមនេះនឹងបង្ហាញពីចំណុចនីមួយៗ និងមតិដែលសាធារណជនបានលើកឡើង៖

| លំនាំ(Pattern) | មតិដែលសាធារណជននិយាយ |
|---|---|
| **មានលុយឈ្នះក្តី (Money = Win)** | ឱ្យតែមានលុយ គឺឈ្នះក្តី។ បើអ្នកក្រ គឺត្រូវតែចាញ់។ សម្តីដ៏ក្រអឺតក្រទមអំពីទឹកប្រាក់ ២០.០០០ ដុល្លារ បានបញ្ជាក់ថា អ្នកមានមើលងាយអាយុជីវិតមនុស្សពេលគឺគ្រាន់តែ «បុកស្លាប់ប៉ុណ្ណឹង បង់លុយឱ្យ ២ម៉ឺនដុល្លារបញ្ចប់រឿង»។ |
| **ការការពារបក្ខពួកតាមរយៈអំណាច (Political Protection)** | ឪពុករបស់បុរសនោះគឺជាអភិបាលស្រុក។ ខ្សែស្រឡាយនយោបាយនេះហើយ ដែលបង្ហាញពីមូលហេតុដែលប៉ូលីសផ្លាស់ប្តូររបាយការណ៍។ អ្នកមានអំណាចតែងតែការពារបក្ខពួករបស់ខ្លួន។ |
| **ប៉ូលីសបម្រើតែអ្នកមាន** | ប៉ូលីសទទួលបានប្រាក់ខែពីពន្ធរបស់ប្រជាពលរដ្ឋ ប៉ុន្តែពួកគេធ្វើការតែសម្រាប់អ្នកមានអំណាចប៉ុណ្ណោះ។ មតិខ្លះលើកឡើងថា ប៉ូលីស «ស៊ីប្រាក់ខែរាស្ត្រ» ប៉ុន្តែមិនបានផ្តល់អ្វីត្រឡប់មកវិញឡើយ។ |
| **យុទ្ធសាស្ត្រប្រើអ្នករងគ្រោះជំនួស (Scapegoat Strategy)** | ស្ត្រីជាដៃគូត្រូវបានចាត់ទុកថាជាអ្នកបើកបរ ដើម្បីទទួលទោសជំនួសបុរសនោះ។ មហាជននិយាយថា នេះគឺជាល្បិចដដែលៗដែលគ្រួសារអ្នកមានអំណាចតែងតែប្រើប្រាស់។ |
| **ការគោរពច្បាប់សម្រាប់តែអ្នកក្រ** | អ្នកបញ្ចេញមតិប្រើពាក្យ «ច្បាប់ស្រុកខ្មែរ» ក្នុងន័យបញ្ចិតបញ្ចៀង (ឌឺដង)។ មានន័យថា ច្បាប់មានប្រសិទ្ធភាពសម្រាប់តែដាក់ទោសអ្នកក្រប៉ុណ្ណោះ ចំណែកអ្នកមានគឺស្ថិតនៅពីលើច្បាប់។ |
| **លំនាំដដែលៗ (Repeated Pattern)** | អ្នកបញ្ចេញមតិជាច្រើននិយាយថា ទង្វើបែបនេះមិនមែនជាលើកទីមួយទេ។ មហាជនមានភាពធុញទ្រាន់នឹងការឃើញរូបភាពដដែលៗនេះ៖ អ្នកមានអំណាចតែងតែគេចផុតពីទោស ចំណែកអ្នកក្រតែងតែរងគ្រោះ។ |

លំនាំដដែលៗទាំង ៦ ខាងលើ បានបង្ហាញនូវសារច្បាស់លាស់មួយពីសាធារណជន ពោលគឺ៖ ពួកគេជឿជាក់ថា ប្រព័ន្ធយុត្តិធម៌នៅកម្ពុជាមាន **«ស្តង់ដារពីរ»** ដោយផ្អែកលើទឹកប្រាក់ និងអំណាច។ លំនាំដែលឃើញមានញឹក

ញាប់បំផុតនោះគឺ **«មានលុយឈ្នះក្ដី»** ដែលមហាជនលើកឡើងថា អ្នកមានអាចប្រើប្រាស់លុយដើម្បីដោះស្រាយរាល់បញ្ហាផ្លូវច្បាប់បានទាំងអស់។

ចំណែកលំនាំដែលឃើញច្រើនបន្ទាប់ទៀតគឺ **«ការការពារបក្ខពួកតាមរយៈអំណាច»** ដោយសារតែជនសង្ស័យគឺជាកូនប្រុសរបស់អភិបាលស្រុក។ មតិយោបល់ជាច្រើនក៏បានចង្អុលបង្ហាញអំពី **«យុទ្ធសាស្ត្រប្រើអ្នករងគ្រោះជំនួស»** ផងដែរ ដោយពួកគេជឿថា ស្ត្រីជាដៃគូត្រូវបានគេប្រើប្រាស់ឱ្យទទួលកំហុសជំនួសបុរសនោះ។ ជាជារួម សាធារណជនមើលឃើញថា ករណីនេះគឺជាភស្តុតាងដែលបញ្ជាក់ថា **ច្បាប់មិនត្រូវបានអនុវត្តដោយស្មើភាពចំពោះមនុស្សគ្រប់គ្នានោះទេ។**

# ៥. ប្រធានបទសំខាន់ៗនៅក្នុងមតិយោបល់

ក្រៅពីបញ្ហាទំនុកចិត្ត និងអំណាច មតិទាំងនេះបានឃើញនៅលើប្រធានបទផ្សេងៗគ្នាជាច្រើន។ តាមរយៈការបែងចែកប្រភេទ យើងបានរកឃើញប្រធានបទខុសៗគ្នាចំនួន ២៨ នៅក្នុងមតិយោបល់ទាំងអស់។ ក្រាហ្វសសរផ្តេកខាងក្រោមបង្ហាញពីប្រធានបទកំពូលៗចំនួន ១០ (ដោយមិនរាប់បញ្ចូលមតិយោបល់ដែលជាប្រតិកម្មទូទៅ)៖




ប្រធានបទលេចធ្លោដែលឈរនៅលេខរៀងទី១ គឺ **«ការទាមទារឱ្យមានភស្តុតាងវីដេអូ/កាមេរ៉ាសុវត្ថិភាព»** (មាន ២៦៣ មតិ)។ មហាជនចង់ឱ្យអាជ្ញាធរត្រួតពិនិត្យរូបភាពកាមេរ៉ាសុវត្ថិភាព (CCTV) នៅកន្លែងកើតហេតុផ្ទាល់ ពីព្រោះពួកគេជឿថាវីដេអូនោះនឹងបញ្ជាក់ថា តើអ្នកណាជាអ្នកបើកបរពិតប្រាកដ។ ប្រធានបទទី២ គឺ **«ការអំពាវនាវរកយុត្តិធម៌»** (មាន ១៥០ មតិ) ដែលមហាជនទាមទារឱ្យមានការដោះស្រាយដោយយុត្តិធម៌សម្រាប់ជនរងគ្រោះ។ ប្រធានបទទី៣ គឺ **«ឥទ្ធិពលនៃទឹកប្រាក់ និងសូកប៉ាន់លើប្រព័ន្ធយុត្តិធម៌»** (មាន ១៤៥ មតិ) ដែលចំណុចនេះមានទំនាក់ទំនងយ៉ាងស្អិតរមួតទៅនឹងលទ្ធផលនៃសំណួរទី២ អំពីអំណាច និងទឹកប្រាក់ធំជាងច្បាប់។

ចំណុចនេះបង្ហាញឱ្យឃើញថា ទោះបីជាសាធារណជនមានការខឹងសម្បារយ៉ាងណាក៏ដោយ ក៏ពួកគេមិនមែនត្រឹមតែបញ្ចេញអារម្មណ៍ប៉ុណ្ណោះនោះទេ។ អ្នកបញ្ចេញមតិជាច្រើនបាន និងកំពុងទាមទារឱ្យមានចំណាត់ការ និងភស្តុតាងជាក់លាក់ ដែលមានន័យថា ពួកគេនៅតែចង់ជឿជាក់ថា **«ការពិត និងភស្តុតាងជាក់ស្តែង»** អាចនាំទៅរកយុត្តិធម៌ពិតប្រាកដបាន។

*សូមមើល **ឧបសម្ព័ន្ធ គ** សម្រាប់ប្រធានបទទាំង ២៨ ព្រមទាំងមតិ សម្រាប់ប្រធានបទនីមួយៗ*

# ៦. សំណួរទី៣៖ តើសាធារណជនចង់ឃើញអ្វីកើតឡើង?

ផ្នែកនេះឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវទី៣៖ តើអ្នកបញ្ចេញមតិចង់ឱ្យមានដំណោះស្រាយបែបណា? ក្នុងចំណោមមតិយោបល់សរុបចំនួន **៣.៧៤៥** មានមតិចំនួន **៧២៥ (១៩,៤%)** បានបង្ហាញពីការចង់ឃើញ ឬការទាមទាររបស់ពួកយ៉ាងច្បាស់លាស់។ ចំណែកឯមតិយោបល់ដែលនៅសេសសល់ គឺជាការបញ្ចេញប្រតិកម្ម ការផ្តល់មតិយោបល់ ឬការបង្ហាញអារម្មណ៍ ដែលមិនមានការទាមទារអ្វីជាក់លាក់នោះទេ។

ក្រាហ្វសសរផ្តេក ខាងក្រោមនេះ បង្ហាញពីប្រភេទនៃការចង់ឃើញនីមួយៗ និងចំនួនអ្នកបញ្ចេញមតិយោបល់៖

### ប្រភេទនៃការចង់ឃើញរបស់អ្នកបញ្ចេញមតិយោបល់ដែលច្រើនជាងគេទាំង១០




ប្រភេទនៃការចង់ឃើញច្រើនជាងគេទាំងពីររបស់មហាជន គឺ **«យុត្តិធម៌សម្រាប់ជនរងគ្រោះ» (១៩៩ មតិ)** និង **«ការត្រួតពិនិត្យរូបភាពកាមេរ៉ាសុវត្ថិភាព/CCTV» (១៩៥ មតិ)**។ ការចង់ឃើញទាំងពីរនេះរួមបញ្ចូលគ្នា មានចំនួនលើសពីពាក់កណ្តាលនៃសំណូមពរសរុបទាំងអស់។ ការចង់ឃើញទីបី គឺ **«ការដាក់ទោសទណ្ឌលើជនដៃដល់ពិតប្រាកដ» (៨៦ មតិ)** ដែលមានន័យថាមហាជនចង់ឱ្យបុរសរូបនោះជាអ្នកទទួលទោស មិនមែនដៃគូរបស់បុរសនោះឡើយ។ ការចង់ឃើញផ្សេងៗទៀតរួមមាន៖ ការស៊ើបអង្កេតឱ្យបានត្រឹមត្រូវ (៥១ មតិ), ការផ្តន្ទាទោសតាមច្បាប់ (៤៩ មតិ) និងមានតម្លាភាព (៤៤ មតិ)។

## ការចង់ឃើញបែងចែកតាមប្រភេទ




នៅពេលដែលយើងបែងចែករាល់ ការចង់ឃើញ ទាំងនោះជាក្រុមៗ ក្រុមដែលធំជាងគេគឺពាក់ព័ន្ធនឹង **ភស្តុតាង និងការស៊ើបអង្កេត**។ នេះរាប់បញ្ចូលទាំងការពិនិត្យកាមេរ៉ាសុវត្ថិភាព ការពិនិត្យស្នាមមេដៃ និងការសាកសួរសាក្សីដែលបានឃើញផ្ទាល់ភ្នែក។ ក្រុមទីពីរគឺអំពី **យុត្តិធម៌ និងការដាក់ទណ្ឌកម្ម** ដែលក្នុងនោះប្រជាជនចង់ឱ្យអ្នកបើកបរពិតប្រាកដជាប់ពន្ធនាគារ ហើយជនរងគ្រោះទទួលបានយុត្តិធម៌។ ក្រុមទីបីគឺអំពី **តម្លាភាព និងភាពស្មោះត្រង់** ដែលប្រជាជនចង់ឱ្យប៉ូលិសបញ្ឈប់ការកុហក ហើយនិយាយការពិត។

ការបែងចែកជាក្រុមបែបនេះបង្ហាញឱ្យយើងឃើញថា សាធារណជនមិនមែនមានត្រឹមតែបញ្ចេញមតិខឹងសម្បានោះទេ។ ពួកគេចង់បានចំណាត់ការជាក់ស្ដែង។ ពួកគេចង់ឱ្យអាជ្ញាធរប្រើប្រាស់ភស្តុតាងដើម្បីស្វែងរកការពិត និងចង់បានការដាក់ទណ្ឌកម្មដោយយុត្តិធម៌ទៅតាមច្បាប់។

# ៧. ការវិភាគលើអារម្មណ៍

ក្រាហ្វសសរផ្ដេក ខាងក្រោមបង្ហាញពីអារម្មណ៍របស់មហាជន នៅពេលដែលពួកគេសរសេរបញ្ចេញមតិយោបល់របស់ពួកគេ។ មតិយោបល់ដែលមានលក្ខណៈកណ្ដាល (២,៣៥៥) ត្រូវបានដកចេញពីក្រាហ្វសនេះ ដើម្បីបង្ហាញពីប្រតិកម្មតាមរយៈអារម្មណ៍ឱ្យកាន់តែច្បាស់។




| ៨៤៨ | ២៨១ | ២៧២ |
|---|---|---|
| មន្ទិលសង្ស័យ | ខកចិត្ត / រិះគន់ | បែបកំប្លែងឡុកឡឺយ (iPhone meme) |

| ទំនោរអារម្មណ៍ | ចំនួន | ភាគរយ | ប្រភេទទំនោរ |
|---|---|---|---|
| កណ្ដាល | ១,៨២៧ | ៤៨.៨% | កណ្ដាល |
| មន្ទិលសង្ស័យ | ៨៤៨ | ២២.៦% | **អវិជ្ជមាន** |
| ខកចិត្ត / រិះគន់ | ២៨១ | ៧.៥% | **អវិជ្ជមាន** |
| បែបកំប្លែងឡុកឡឺយ | ២៧២ | ៧.៣% | **ឡាយលំ (iPhone meme)** |
| បែបឌឺដង / បញ្ចើចបញ្ចើ | ១២២ | ៣.៣% | **អវិជ្ជមាន** |
| អស់កម្លាំងចិត្ត / មួម៉ៅ | ៨៥ | ២.៣% | **អវិជ្ជមាន** |
| អស់ជំនឿ | ៨៣ | ២.២% | **អវិជ្ជមាន** |

| | | | |
|---|---|---|---|
| មួម៉ៅ / ខឹងសម្បារ | ៧០ | ១.៩% | **អវិជ្ជមាន** |
| មានសង្ឃឹម | ៦០ | ១.៦% | **វិជ្ជមាន** |
| ក្រៀមក្រំ / អាណិតអាសូរ | ៣១ | ០.៨% | **អវិជ្ជមាន** |
| ខឹងសម្បារ / រករឿង | ២៨ | ០.៧% | **អវិជ្ជមាន** |
| ខឹងសម្បារ / ធុញទ្រាន់ខ្លាំង | ២៦ | ០.៧% | **អវិជ្ជមាន** |
| មានសង្ឃឹម / វិជ្ជមាន | ៧ | ០.២% | **វិជ្ជមាន** |
| ខកចិត្ត | ៥ | ០.១% | **អវិជ្ជមាន** |

# ៨. សេចក្ដីសន្និដ្ឋាន

**រកឃើញចំណុចសំខាន់ៗ៖ ជំនឿទុកចិត្តរបស់សាធារណជនមានកម្រិតទាបបំផុត**

ការវិភាគលើមតិយោបល់ចំនួន ៣,៧៤៥ នៅលើបណ្ដាញសង្គម Facebook បង្ហាញថា អ្នកបញ្ចេញមតិមានជំនឿទុកចិត្តទាបបំផុតទៅលើអាជ្ញាធរដែលកាន់សំណុំរឿងនេះ។ មូលហេតុចម្បងៗគឺ៖ ភាពមិនស៊ីគ្នារវាងរបាយការណ៍ប៉ូលិស និងភស្តុតាងវីដេអូ, អាកប្បកិរិយាច្រងេងច្រងាងរបស់អ្នកបើកបរដែលយល់ថា "បុកស្លាប់ហើយបង់លុយ" ចំពោះជីវិតមនុស្ស, ទំនាក់ទំនងនយោបាយរបស់បុរសដែលស្រវឹងស្រា និងទម្លាប់ដែលអ្នកមានអំណាចតែងតែគេចផុតពីសំណាញ់ច្បាប់។

ប្រជាជនមិនមែនខឹងសម្បារត្រឹមតែចំពោះករណីមួយនេះនោះទេ។ ពួកគេមើលឃើញថា វាជាផ្នែកមួយនៃបញ្ហាដ៏ធំនៅក្នុងប្រព័ន្ធយុត្តិធម៌។ ពួកគេជឿថា លុយកាក់ និងអំណាច អាចផ្លាស់ប្ដូរលទ្ធផលនៃសំណុំរឿងតាមផ្លូវច្បាប់បាន។

ទោះជាយ៉ាងណាក៏ដោយ មនុស្សជាច្រើននៅតែបន្តទាមទារនូវចំណុចជាក់លាក់មួយចំនួន រួមមាន៖ ការពិនិត្យរូបភាពវីដេអូកាមេរ៉ាសុវត្ថិភាព ការពិនិត្យស្នាមក្រយៅដៃ និងការសាកសួរសាក្សី។ នេះសបញ្ជាក់ឱ្យឃើញថា ទោះបីជាជំនឿទុកចិត្តមានកម្រិតទាបក៏ដោយ ក៏ប្រជាជននៅតែចង់ជឿថា ភស្តុតាង និងការពិត អាចនាំទៅរកយុត្តិធម៌បាន។

### សង្ខេបចម្លើយទាំងពសំណួរ

| សំណួរ | ចម្លើយខ្លីៗ | ចម្លើយបន្ថែម |
|---|---|---|
| **តើសាធារណជនមានទំនុកចិត្តលើអាជ្ញាធរដែរឬទេ?** | **មិនទុកចិត្តទេ** | ក្នុងចំណោមមតិយោបល់ចំនួន ២,០៨៦ មាន ៩៥% គឺមិនមានជំនឿទុកចិត្ត។ អាកប្បកិរិយាច្រងេងច្រងាង "បុកស្លាប់ហើយបង់លុយ" របស់អ្នកបើកបរ, របាយការណ៍ប៉ូលិសដែលមិនពិត, និងទំនាក់ទំនងនយោបាយ គឺជាបុព្វហេតុដែលធ្វើឱ្យសាធារណជនខឹងសម្បារ។ |
| **តើមហាជនយល់ឃើញយ៉ាងណាចំពោះ «អំណាចធំជាងច្បាប់»?** | **អំណាចឈ្នះច្បាប់** | ប្រជាជនជឿថា លុយកាក់ និងទំនាក់ទំនងនយោបាយ គឺស្ថិតនៅពីលើច្បាប់។ ពួកគេមើលឃើញថា នេះគឺជាទម្លាប់ដែលកើតឡើងដដែលៗនៅទូទាំងប្រទេសកម្ពុជា។ |
| **តើសាធារណជនចង់ឃើញអ្វីកើតឡើង?** | **យុត្តិធម៌** | ការទាមទារសំខាន់ៗ៖ យុត្តិធម៌សម្រាប់ជនរងគ្រោះ (១៩៩), ការពិនិត្យកាមេរ៉ាសុវត្ថិភាព (១៩៥), ការដាក់ពន្ធនាគារអ្នកបើកបរពិតប្រាកដ (៨៦) និងការស៊ើបអង្កេតឱ្យបានត្រឹមត្រូវ (៥១ )។ |